ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

Asia Euro University

លេខ:........០៥៣ សអន...

## និតិវិធីនៃការរៀបចំផែនការយុទ្ធសាស្ត្រ
## ដើម្បីប្រមូលនិស្សិតចូលសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- យោងសេចក្តីជូនដំណឹងលេខ 04/05 គទកសជណ ចុះថ្ងៃទី 30មិនាឆ្នាំ 2005របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា ស្តីពីការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- យោងសេចក្តីណែនាំលេខ 48/05 គទកសជណ ចុះថ្ងៃទី28 វិច្ឆិកា 2005ស្តីពីការអនុញ្ញាតដល់គ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ដើម្បីអនុវត្តដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- យោងតាមផែនការយុទ្ធសាស្ត្រលេខ០៤៨ចុះថ្ងៃទី២២.៨.៥របស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុបស្តីពីការប្រមូលនិស្សិតចូលសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

- យោងតាមស្មារតីអង្គប្រជុំរបស់គណៈគ្រប់គ្រងសាកលវិទ្យាល័យ អាស៊ី អឺរ៉ុបកាលពីថ្ងៃ.១៥.ខែ.ធ្នូ.២០០៥

-គណៈគ្រប់គ្រងរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប សូមលើកនូវនិតិវិធីសំរាប់អនុវត្តនូវផែនការយុទ្ធសាស្ត្រដើម្បីប្រមូលនិស្សិតចូលសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដូចខាងក្រោម៖

1-ប្រធានការិយាល័យសិក្សាស្រាវជ្រាវ ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងនៃគ្រប់មហាវិទ្យាល័យ បុគ្គលិកតាមផ្នែកចំណុះត្រូវចូលរួមប្រជុំ រួមតាមការកំណត់ គណៈគ្រប់គ្រងសាកលវិទ្យាល័យ នៅរៀងរាល់ 1ខែមុនពេលត្រូវចុះបើកយុទ្ធនាការផ្សព្វផ្សាយ ដើម្បីប្រមូលផ្តុំនូវរាល់ពត៌មានសំខាន់ៗចាំបាច់មួយចំនួនសំរាប់រៀបចំនូវយុទ្ធនាការនេះ។

2-រាល់ខ្លឹមសារដែលត្រូវយកមកផ្សព្វផ្សាយ ត្រូវធ្វើអោយខ្លី តែស៊ីជំរៅ ការរៀបចំរចនាបទធ្វើយ៉ាងណាអោយអ្នកអានចាប់អារម្មណ៍មធ្យោបាយដែលត្រូវទំនាក់ទំនងបង្កើតអោយមានយ៉ាងទូលំទូលាយ។

3-រាល់ឯកសារត្រូវយកទៅផ្សព្វផ្សាយ ត្រូវបំពេញអោយគ្រប់គ្រាន់យ៉ាងយឺតបំផុត១សប្តាហ៍នៅមុនពេលចុះយុទ្ធនាការដើម្បីធ្វើការត្រួតពិនិត្យនិងកែសំរួលឡើងវិញនូវរាល់ខ្លឹមសារនិងរាល់ចំនុចខុសឆ្គងដែលកើតមានឡើង។

4-គោលដៅដែលត្រូវចុះផ្សព្វផ្សាយនិមួយៗចាំបាច់ត្រូវដឹកនាំដោយគណៈកម្មការមួយក្រុមដែលក្នុងនោះមានសមាសភាពពី3ទៅ5រូបហើយដឹកនាំដោយគណៈគ្រប់គ្រងមួយរូប

5-គោលដៅដែលត្រូវចុះផ្សព្វផ្សាយ អនុវត្តនៅគ្រប់វិទ្យាល័យ គ្រប់មណ្ឌលប្រលងបញ្ចប់ថ្នាក់ទី 12 ដែលមាននៅទីក្រុងភ្នំពេញ-ក្រុងកំពង់សោម ខេត្តកណ្តាលខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកំពង់ចាម ខេត្តព្រៃវែង និងខេត្តកំពង់ធំ។

6-ពេលវេលាត្រូវបើកយុទ្ធនាការផ្សព្វផ្សាយមានរយៈពេល 3ខែ ដោយបែងចែកជា 3ដំណាក់កាល

-1ខែមុនប្រលង ផ្សព្វផ្សាយប្រយោលជាមួយសិស្សតាមរយៈការចងបដាផ្សព្វផ្សាយ តាមសារពត៌មានតាមទស្សនាវដ្តី តាមរលកធាតុអាកាស (វិទ្យុ ទូរទស្សន៍) តាម Internet.

-កំឡុងពេលត្រូវប្រលងយើង ផ្សព្វផ្សាយ ផ្ទាល់ជាមួយសិស្ស តាមរយៈការចែកប័ណ្ណផ្សព្វផ្សាយនៅពេលសិស្សមកមើលឈ្មោះប្រលង នៅគ្រប់ពេលនិងគ្រប់ថ្ងៃដែលសិស្សសំរាកពីការប្រលងនិងនៅថ្ងៃប្រកាសលទ្ធផលប្រលង។

-1ខែក្រោយពេលប្រកាសលទ្ធផលប្រលងរួចហើយយើងធ្វើការផ្សព្វផ្សាយ ប្រយោលផងគួបផ្សំនឹងការផ្សព្វផ្សាយផ្ទាល់ជាមួយសិស្ស និងជាមួយអាណាព្យាបាលរបស់សិស្សផង។

7-ក្រោយពេលយុទ្ធនាកាផ្សព្វផ្សាយរួចមកយើងនៅបន្តផ្សព្វផ្សាយតាមរយៈប្រយោលជាប្រចាំម្តងទៀតសំដៅអោយការផ្សព្វផ្សាយកាន់តែបានជ្រួតជ្រាបស៊ីជំរៅ និងទូលំទូលាយ នៅទូទាំងប្រទេស។

8-ទន្ទឹមនិងការផ្សព្វផ្សាយ យើងបានបង្កើតក្រុមស្រាវជ្រាវដាច់ដោយឡែក ផ្សេងទៀត ដែលត្រូវចុះដល់មូលដ្ឋាននានាដើម្បីប្រមូលយកមតិស្នាបស្ទង់ពីសិស្ស អាណាព្យាបាលសិស្ស និងមជ្ឈដ្ឋាននានា សំដៅស្វែងរកនូវចំនុចដែលត្រូវរិះគន់ផងនិងពន្យល់នូវរាល់ចំងល់ដែលត្រូវចុះឈ្មោះចូលរៀននៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ផងដែរ។

9-នៅគ្រប់ពេលសិស្សបានមកចុះឈ្មោះចូលសិក្សា សាកលវិទ្យាល័យ តែងតែមានគោលការណ៍លើកទឹកចិត្តដល់គ្រប់សិស្សម្នាក់ៗតាមគ្រប់រូបភាព សំដៅអោយសិស្សទាំងនោះក្លាយជាអ្នកជួយផ្សព្វផ្សាយបន្តបានយ៉ាងងាយស្រួល និងកាន់តែមានទំនុកចិត្តដល់អ្នកដទៃដែលពុំទាន់បានចុះឈ្មោះសិក្សានៅឡើយ។

10-បង្កើននូវភាពទំនុកចិត្តយ៉ាងរឹងមាំរបស់សាលា តាមគ្រប់រូបភាពជូនដល់គ្រប់មជ្ឈដ្ឋានសិស្សឬអាណាព្យាបាលរបស់ពួកគេដែលបានចុះឈ្មោះរៀនរួចហើយ ដើម្បីការជាស្ពានក្នុងការអូសទាញ សិស្សផ្សេងទៀតអោយចូលសិក្សាបន្ថែម។

11-ពេលចប់សកម្មភាពយុទ្ធនាកាម្តងៗ គណៈកម្មាការនិមួយៗ ត្រូវប្រជុំដកពិសោធន៍ការងារដើម្បីស្វែងរកនូវចំនុចរីកចំរើន សំរាប់អនុវត្តបន្ត។

12-គ្រប់សមាសភាពដែលចុះធ្វើសកម្មភាព តែងតែទទួលបាននូវការលើកទឹកចិត្ត នូវរាល់ស្នាដៃដែលបានទទួលបាន។

13-ពេលវេលាចុះផ្សព្វផ្សាយបន្ត អនុវត្តនូវពេល ដែលមានការណែនាំពីគណៈគ្រប់គ្រងជាថ្មី។

ថ្ងៃទី.២២.ខែ.ធ្នូ.ឆ្នាំ200៥

សាកលវិទ្យាធិការ

ឡុង_សារ៉ះ

ចំលងជូន

-គណៈកម្មាធិការ ACC

ជូនជ្រាប

-គ្រប់ការិយាល័យសិក្សានិងស្រាវជ្រាវ

-គ្រប់ផ្នែកចំណុះការិយាល័យ សិក្សាស្រាវជ្រាវដើម្បីអនុវត្ត

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

Asia Euro University

លេខ:....០៤១...សអឺ.....
ឋប

ផែនការយុទ្ធសាស្ត្រដើម្បីប្រមូលនិស្សិត

អោយចូលសិក្សា ថ្នាក់សិក្សាថ្នាក់មូលដ្ឋាន

- យោងសេចក្តីជូនដំណឹងលេខ 04/05 គទកសជណ ចុះថ្ងៃទី 30មិនាឆ្នាំ 2005របស់គណ:កម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា ស្តីពីការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- យោងសេចក្តីណែនាំលេខ 48/05 គទកសជណ ចុះថ្ងៃទី28 វិច្ឆិកា 2005ស្តីពីការអនុញ្ញាតដល់គ្រប់ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ដើម្បីអនុវត្តដំណើរការថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- ដើម្បីធានានូវគុណភាពអប់រំថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន អោយមានលក្ខណ:ល្អប្រសើរ

គណ:គ្រប់គ្រងសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប សូមលើកនូវផែនការយុទ្ធសាស្ត្រដើម្បីប្រមូលនិស្សិត អោយចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដូចមានខ្លឹមសារខាងក្រោម ៖

1-<u>រយ:ពេលនៃការបើកយុទ្ធនាការផ្សព្វផ្សាយ</u>

- ជារៀងរាល់ឆ្នាំនិមួយៗត្រូវដំណើរការផ្សព្វផ្សាយរយ:ពេលបីខែដោយអនុវត្តនូវចន្លោះពេលដែលសិស្សវិទ្យាល័យបញ្ចប់ថ្នាក់(វិស្សមកាល)និងត្រៀមប្រលងបញ្ចប់ថ្នាក់ទី12 រហូតដល់ពេលចាប់ផ្តើម បើកបវេសនកាលឆ្នាំថ្មី ។

- ចុងវគ្គយុទ្ធនាការនិមួយៗ នឹងមានការប្រជុំបូកសរុប លទ្ធផលការងារដែលអនុវត្តបាន ប្រជុំ ដកពិសោធន៍ការងារ ដើម្បីស្វែង រកចំនុចខ្លាំង ខ្សោយ និង កែលំអរចំនុចខ្វះខាត ...........។ល។

- ជារៀងរាល់ 3 ឆ្នាំម្តង និងមានការប្រជុំបូកសរុបរួម ដើម្បីលើកផែនការយុទ្ធសាស្ត្រសំរាប់3ឆ្នាំបន្ទាប់។

2-គោលដៅក្នុងការបើកយុទ្ធសាស្ត្រផ្សព្វផ្សាយ

- អនុវត្តនៅទីក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ចាម តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពត ក្រុងព្រះសីហនុ ក្រុងកែប ព្រៃវែង និង កំពង់ធំ ។

- ផ្សព្វផ្សាយ ចំពោះតែសិស្សបានបញ្ចប់ថ្នាក់ទី 12 ប៉ុណ្ណោះ។

3-<u>យុទ្ធវិធីនៃការផ្សព្វផ្សាយ</u>

ផ្សព្វផ្សាយតាមរយ:

- ចុះចែកប័ណ្ណផ្សព្វផ្សាយដល់ទីកន្លែង
- បដាផ្សព្វផ្សាយតាមចំនុចគោលដៅ
- ចុះផ្សាយតាមសារពត៌មាន ទស្សនាវដ្តី
- រលកធាតុអាកាស (វិទ្យុ ទូរទស្សន៍)
- Internet
- និស្សិតដែលធ្លាប់រៀននៅ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- ការចុះកម្មសិក្សារបស់និស្សិត
- តាមស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល

4-<u>យុទ្ធវិធីនៃការចុះផ្សព្វផ្សាយ</u>

- គ្រប់ពេលចុះយុទ្ធនាកាផ្សព្វផ្សាយម្តងៗ ចាំបាច់ត្រូវមានគណ:កម្មាការដឹកនាំច្បាស់លាស់។

- គ្រប់គណ:កម្មាការដឹកនាំ ចាំបាច់ត្រូវប្រជុំរួម ដើម្បីទទួលនូវផែនការលំអិត ពីគណ:គ្រប់គ្រងរបស់សាកលវិទ្យាល័យជាមុន មុនពេលចុះបំពេញបេសកកម្ម។

ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ200៥

សាកលវិទ្យាធិការ ៖

ឌុច_សារុន

ចំលងជូន

-គណ:កម្មាធិការ ACC

<u>ជូនជ្រាប</u>

-ការិយាល័យរដ្ឋបាល សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-ការិយាល័យ សិក្សាស្រាវជ្រាវតាមសាខា

<u>ដើម្បីអនុវត្ត</u>

-ឯកសារកាលប្បវត្តិ